**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១១២.អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ប្រព័ន្ធផ្លាស់ប្ដូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ០៥ ន/ស ៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១០/០០៩ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹក
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកំណត់និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល

- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន្តចូលចេញនិងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីហត្ថលេខាឌីជីថល
- បានឃើញអនុក្រឹត្យលេខ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការនិងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែនសាធារណការនិងដឹកជញ្ជូនរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យានិងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យានិងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការគ្រប់គ្រងដំណើរការប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ដើម្បីបង្កលក្ខណៈងាយស្រួលនិងភាពឆាប់រហ័ស ក្នុងការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ និងការធ្វើបែបបទនាវាចូលចេញប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ស្របតាមបរិវត្តកម្មឌីជីថលក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ នាវាដែលចូលចេញកំពង់ផែនិងការធ្វើបែបបទនាវាតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**កំពង់ផែ** សំដៅដល់តំបន់ដែលមានដែនទឹកនិងដែនគោក ដែលមានឋបនីយភណ្ឌផែសម្រាប់បម្រើឱ្យនាវាចូល ចេញ បោះយុថ្កា សម្រាល ចងញួរ បត់ ចត លើក ដាក់ ផ្ទេរ ផ្ទុក រក្សាទុកទំនិញ និងផ្ទេរ ផ្ទុកអ្នកដំណើរសម្រាប់ធ្វើពាណិជ្ជកម្មឬសហគ្រាសផ្ទាល់។

**ការធ្វើបែបបទនាវា** សំដៅដល់ការបំពេញព័ត៌មានស្នើសុំឱ្យនាវាចូលចេញកំពង់ផែ និងឯកសារភ្ជាប់តាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

**កណ្ណធារ** សំដៅដល់អ្នកនាំផ្លូវនាវាដែលមានភារកិច្ចជួយដល់មេបញ្ជាការនាវាដើម្បីធ្វើនាវាចរប្រកបដោយសុវត្ថិភាពនៅក្នុងមណ្ឌលកណ្ណធារកិច្ច។

**នាវា** សំដៅដល់មធ្យោបាយដឹកជញ្ជូនផ្លូវទឹក ដែលធ្វើនាវាចរជាលក្ខណៈអន្តរជាតិឬទ្វេភាគី ដោយមិនរាប់បញ្ចូលនាវាយោធានិងនាវាសង្គ្រោះ។

**និវេទនបណ្ណ** សំដៅដល់បញ្ជីប្រកាសរាយមុខទំនិញ។

**ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ** សំដៅដល់ប្រព័ន្ធបច្ចេកវិទ្យាផ្លូវការ ដើម្បីសម្របសម្រួលបែបបទនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ និងការធ្វើបែបបទនាវាជាទម្រង់អេឡិចត្រូនិកដូចមានចែងក្នុងអនុក្រឹត្យនេះ។

**ភ្នាក់ងារនាវា** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលផ្តល់សេវាទាក់ទងនឹងការចូលចេញនាវានៅតាមកំពង់ផែក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

**ម្ចាស់នាវា** សំដៅដល់បុគ្គលដែលមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើនាវា រួមមានបុគ្គលដែលជាម្ចាស់លើនាវាផ្ទាល់ខ្លួន ក្រុមហ៊ុននាវា ឬម្ចាស់នាវាភារវេទកិច្ច។ ម្ចាស់នាវាភារវេទកិច្ចជាបុគ្គលដែលទទួលសិទ្ធិគ្រប់គ្រងនិងធ្វើប្រតិបត្តិការនាវាតាមរយៈកិច្ចសន្យាជួល។

**លិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែ** សំដៅដល់លិខិតចេញឱ្យនាវាចេញពីកំពង់ផែ បន្ទាប់ពីម្ចាស់នាវាបំពេញបែបបទនាវាចេញ និងត្រូវបានឯកភាពពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។ លិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែ ត្រូវបានប្រើសម្រាប់បង្ហាញសមត្ថកិច្ចនៅកំពង់ផែគោលដៅបន្ទាប់ទៀត។

**លិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ** សំដៅដល់លិខិតចេញឱ្យនាវាចូលកំពង់ផែ បន្ទាប់ពីក្រុមហ៊ុននាវាឬភ្នាក់ងារនាវាស្នើសុំបំពេញបែបបទនាវាចូលនិងត្រូវបានឯកភាពពីក្រសួងសាធារណការនិងដឹកជញ្ជូន។ លិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ ត្រូវបានប្រើសម្រាប់បង្ហាញដល់គណៈកម្មការធ្វើបែបបទនាវាចូលមុននឹងអនុញ្ញាតការធ្វើបែបបទនាវាចូលកំពង់ផែ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៤.-**

ក្រសួងសាធារណការនិងដឹកជញ្ជូនជាស្ថាប័នមានសមត្ថកិច្ចលើការដឹកនាំ ធ្វើទំនើបកម្ម ថែទាំ និងគ្រប់គ្រងប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែនៃក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទទួលបន្ទុកសម្របសម្រួលលើការអនុវត្តប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ និងមានភារកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា តាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ត្រូវទទួលបន្ទុកសហការជាមួយអគ្គនាយកដ្ឋានបច្ចេកវិទ្យានិងទំនាក់ទំនងសាធារណៈនៃក្រសួងសាធារណការនិងដឹកជញ្ជូនលើការរៀបចំថែទាំ និងធ្វើទំនើបកម្មប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

**មាត្រា៥ .-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ ឬកំពង់ផែផ្សេងទៀត ត្រូវទទួលខុសត្រូវតាមសមត្ថកិច្ចរៀងៗខ្លួនស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងការត្រួតពិនិត្យនិងផ្តល់ការយល់ព្រមលើភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារសម្រាប់ការធ្វើបែបបទនាវា។

ទម្រង់ឯកសារគោលចំនួន៧(ប្រាំពីរ) ដែលភ្នាក់ងារមានសមត្ថកិច្ចជំនាញដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើការត្រួតពិនិត្យនិងផ្តល់ការយល់ព្រមតាមសមត្ថកិច្ចរៀងៗខ្លួនមានដូចខាងក្រោម៖

១- ប្រតិវេទន៍ទូទៅ។

២- ប្រតិវេទន៍ទំនិញបំព្រួញ។

៣- ប្រតិវេទន៍សន្និធិនាវា។

៤- ប្រតិវេទន៍សម្ភារៈផ្ទាល់ខ្លួនរបស់ក្រុមនាវិក។

៥- និវេទនបណ្ណទំនិញគ្រោះថ្នាក់។

៦- បញ្ជីឈ្មោះក្រុមនាវិក។

៧- បញ្ជីឈ្មោះអ្នកដំណើរ។

ការផ្លាស់ប្តូរឬកែប្រែប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ត្រូវសម្រេចដោយរាជរដ្ឋាភិបាលតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៦ .-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ ឬកំពង់ផែផ្សេងទៀតមានភារកិច្ច៖

១- ជូនដំណឹងរាល់ភាពមិនប្រក្រតីអំពីដំណើរប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ទៅក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងរយៈពេលមិនលើសពី២៤(ម្ភៃបួន)ម៉ោង។

២- ចងក្រងនិងរក្សាទុករបាយការណ៍និងឯកសារពាក់ព័ន្ធនឹងការធ្វើបែបបទនាវាចូលចេញនិងលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

## ជំពូកទី៣
## ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ

**មាត្រា៧ .-**

ការផ្លាស់ប្តូរព័ត៌មាននិងឯកសារសម្រាប់នាវាចូលចេញកំពង់ផែ ត្រូវអនុវត្តតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

គំនូសបំព្រួញប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ មានភ្ជាប់ជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

ឯកសារដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ត្រូវភ្ជាប់ប្រព័ន្ធផ្ទៀងផ្ទាត់គល់បញ្ជីនិង/ឬហត្ថលេខាឌីជីថល ដើម្បីធានាសុវត្ថិភាព សុចរិតភាព និងសុក្រឹតភាពនៃទិន្នន័យ ព្រមទាំងត្រូវមានកំណត់ត្រាក្នុងប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

**មាត្រា៩ .-**

រាល់ទិន្នន័យនៅក្នុងប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ មិនត្រូវផ្តល់ឬចែកចាយ ដោយគ្មានការអនុញ្ញាតពីក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១០ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬអ្នកពាក់ព័ន្ធអំពីការអនុវត្តនីតិវិធីបណ្តោះអាសន្ន ក្នុងករណីប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែមិនដំណើរការ។

នីតិវិធីបណ្តោះអាសន្ន ត្រូវអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## លក្ខខណ្ឌ បែបបទ នីតិវិធី និងកម្រៃសេវាសាធារណៈនៃការស្នើសុំនាវាចូលចេញ
### ផ្នែកទី១
### លក្ខខណ្ឌនៃការស្នើសុំធ្វើបែបបទនាវាចូលចេញ

**មាត្រា១១ .-**

ម្ចាស់នាវាឬភ្នាក់ងារនាវា ត្រូវបំពេញពាក្យស្នើសុំនាវាចូលចេញតាមទម្រង់និងបែបបទតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ធានាភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារដែលបានបំពេញតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច
- ត្រូវផ្តល់ព័ត៌មាននិងបំពេញលក្ខខណ្ឌតម្រូវនានាមកក្រសួង ស្ថាប័នមានសមត្ថកិច្ច
- សហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចក្នុងករណីមានការតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បង់កម្រៃសេវាសាធារណៈពាក់ព័ន្ធ។

**មាត្រា១២ .-**

នៅពេលនាវាចូលកំពង់ផែ ម្ចាស់នាវាឬភ្នាក់ងារនាវាត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖

- ត្រូវជូនព័ត៌មានជាមុនតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ អំពីការមកដល់របស់នាវា ឬមុននាវាចូលដល់កន្លែងបោះយុថ្កា រយៈពេល៧២(ចិតសិបពីរ)ម៉ោង ឬ៤៨(សែសិបប្រាំបី)ម៉ោង ឬ ២៤(ម្ភៃបួន)ម៉ោង
- ត្រូវមានការឯកភាពពីសមត្ថកិច្ចកំពង់ផែ
- ត្រូវស្នើសុំលិខិតអនុញ្ញាតឱ្យនាវាចូល ជូនព័ត៌មានមុននាវាមកដល់ ស្នើសុំកណ្តាជារ និងធ្វើបែបបទនាវាចូលកំពង់ផែ។

**មាត្រា១៣ .-**

នៅពេលនាវាចេញពីកំពង់ផែ ម្ចាស់នាវាឬភ្នាក់ងារនាវាត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖

- ត្រូវជូនព័ត៌មានជាមុនតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែអំពីការស្នើសុំនាវាចេញពីកំពង់ផែ ក្នុងរយៈពេលយ៉ាងតិច១២(ដប់ពីរ)ម៉ោង
- ត្រូវមានការឯកភាពពីសមត្ថកិច្ចកំពង់ផែ
- ត្រូវស្នើសុំកណ្ណជារនិងធ្វើបែបបទនាវាចេញពីកំពង់ផែ។

**មាត្រា១៤ .-**

គំនូសបំព្រួញនៃការស្នើសុំការធ្វើបែបបទនាវាតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ មានភ្ជាប់ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## ទម្រង់ពាក្យស្នើសុំការធ្វើបែបបទនាវាចូលចេញ

**មាត្រា១៥ .-**

ទម្រង់ពាក្យស្នើសុំការធ្វើបែបបទនាវាចូលកំពង់ផែតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ត្រូវបានកំណត់ដូចខាងក្រោម៖

១- លិខិតអនុញ្ញាតស្នើសុំឱ្យនាវាចូល។
២- ការជូនព័ត៌មានមុននាវាមកដល់។
៣- ការជូនព័ត៌មានជាមុនស្តីពីសន្តិសុខនាវា។
៤- ប្រតិវេទន៍សន្តិសុខនាវា។
៥- ការស្នើសុំកណ្ណជារ។
៦- វិញ្ញាបនបត្រត្រួតពិនិត្យអនាម័យនាវា/វិញ្ញាបនបត្រលើកលែងអនាម័យនាវា។
៧- ប្រតិវេទន៍នាវាមកដល់ ដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា៥នៃអនុក្រឹត្យនេះ។

**មាត្រា១៦ .-**

ទម្រង់ពាក្យស្នើសុំការធ្វើបែបបទនាវាចេញកំពង់ផែតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការស្នើសុំកណ្ណជារ។
២- ប្រតិវេទន៍នាវាចេញ ដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា៥នៃអនុក្រឹត្យនេះ។

## ផ្នែកទី៣
## នីតិវិធីនៃការស្នើសុំធ្វើបែបបទនាវា

**មាត្រា១៧ .-**

ម្ចាស់នាវាឬភ្នាក់ងារនាវាត្រូវស្នើសុំការធ្វើបែបបទនាវា ដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវតាមលក្ខខណ្ឌក្នុងទម្រង់អេឡិចត្រូនិកដែលមានកំណត់ក្នុងគេហទំព័រប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

ម្ចាស់នាវា អាចផ្ទេរសិទ្ធិឱ្យអ្នកតំណាងឬភ្នាក់ងារនាវាណាមួយ ដើម្បីស្នើសុំការធ្វើបែបបទនាវា ដោយមានភ្ជាប់មកជាមួយនូវឯកសារផ្ទេរសិទ្ធិឱ្យអ្នកតំណាង ឬភ្នាក់ងារនាវា ឯកសារពាក់ព័ន្ធស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៨ ._**

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្ទៀងផ្ទាត់ព័ត៌មាននិងឯកសារភ្ជាប់តាមក្រសួង ស្ថាប័នមានសមត្ថកិច្ចនីមួយៗ។ ក្នុងករណីព័ត៌មាននិងឯកសារភ្ជាប់មិនត្រឹមត្រូវនិង/ឬមិនគ្រប់គ្រាន់ ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវជូនព័ត៌មានដល់ម្ចាស់នាវាឬភ្នាក់ងារនាវា ដើម្បីធ្វើការកែតម្រូវឬបំពេញបន្ថែម។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវផ្តល់វិញ្ញាបនបត្រ លិខិតបញ្ជាក់ ឬលិខិតអនុញ្ញាត ដោយគិតចាប់ពីថ្ងៃដែលម្ចាស់នាវាឬភ្នាក់ងារនាវាស្នើសុំ បានធ្វើការកែតម្រូវឬបំពេញបន្ថែម។

## ផ្នែកទី៤

## កម្រៃសេវាសាធារណៈ

**មាត្រា១៩ ._**

រាល់ការស្នើសុំលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែឬសកម្មភាពពាក់ព័ន្ធផ្សេងទៀត ត្រូវបង់កម្រៃសេវា។

កម្រៃសេវាលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែឬសេវាសាធារណៈពាក់ព័ន្ធផ្សេងទៀត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## ការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រនិងលិខិតអនុញ្ញាត

## ផ្នែកទី១

## ការផ្តល់វិញ្ញាបនបត្រនិងលិខិតអនុញ្ញាត

**មាត្រា២០ ._**

ការស្នើសុំលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ ត្រូវធ្វើឡើងឱ្យបានមុន២៤(ម្ភៃបួន)ម៉ោង មុនពេលនាវាចូលមកដល់កំពង់ផែ។

**មាត្រា២១ ._**

ក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចធ្វើបែបបទឱ្យនាវាចូលកំពង់ផែបាន លុះត្រាតែនាវាមានលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ។

**មាត្រា២២ ._**

កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ ឬកំពង់ផែផ្សេងទៀត ត្រូវចេញលិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រោយមានការឯកភាពលើបែបបទនាវាចេញរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា២៣ ._**

វិញ្ញាបនបត្រនិងលិខិតអនុញ្ញាតពាក់ព័ន្ធនឹងការធ្វើបែបបទនាវារបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវចេញជាទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានសម្រាប់ប្រើជាផ្លូវការតាមគេហទំព័រប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

វិញ្ញាបនបត្រនិងលិខិតអនុញ្ញាតពាក់ព័ន្ធនឹងការធ្វើបែបបទនាវា ក្នុងទម្រង់ឌីជីថល អាចផ្ទៀងផ្ទាត់ទិន្នន័យបឋមតាមគេហទំព័ររបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងអាចបន្តផ្ទៀងផ្ទាត់ទិន្នន័យលម្អិតតាមគេហទំព័រប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

## ផ្នែកទី២

## ការព្រមាន ការព្យួរ ឬការដកហូតវិញ្ញាបនបត្រនិងលិខិតអនុញ្ញាត

**មាត្រា២៤.-**

រាល់ការប្រព្រឹត្តល្មើសដោយម្ចាស់នាវាឬដោយភ្នាក់ងារនាវាទៅនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវចាត់វិធានការដូចខាងក្រោម៖

- ធ្វើការព្រមាននិងតម្រូវឱ្យកែសម្រួលតាមការណែនាំឡើងវិញ
- ព្យួរឬដកហូតវិញ្ញាបនបត្រនិងលិខិតអនុញ្ញាត
- អនុវត្តវិធានការពាក់ព័ន្ធផ្សេងទៀត តាមការកំណត់របស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា២៥.-**

ការព្យួរឬការដកហូតវិញ្ញាបនបត្រនិងលិខិតអនុញ្ញាត ត្រូវអនុវត្តចំពោះម្ចាស់នាវាឬភ្នាក់ងារនាវាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម៖

១- មិនគោរពតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងអនុក្រឹត្យនេះ។

២- ផ្តល់ព័ត៌មានមិនពិតឬប្រើឯកសារក្លែងក្លាយ។

៣- ប្រព្រឹត្តល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នីតិវិធីព្យួរ ដកហូត ឬលុបចោលនូវវិញ្ញាបនបត្រនិងលិខិតអនុញ្ញាតនានា ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦

## ម្ចាស់នាវាឬភ្នាក់ងារនាវា

## ផ្នែកទី១

## ភារកិច្ចរបស់ម្ចាស់នាវាឬភ្នាក់ងារនាវា

**មាត្រា២៦.-**

ម្ចាស់នាវាឬភ្នាក់ងារនាវា ត្រូវស្នើសុំបង្កើតគណនីប្រើប្រាស់ តាមទម្រង់និងបែបបទដែលកំណត់ក្នុងគេហទំព័រប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ នៃក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៧.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិបដិសេធផ្តល់គណនីប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ក្នុងករណីម្ចាស់នាវាឬភ្នាក់ងារនាវាមិនបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២៨.-**

ម្ចាស់នាវាឬភ្នាក់ងារនាវា ត្រូវ៖

- ធានាថា រាល់ការស្នើសុំលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ និងការធ្វើបែបបទនាវា មិនត្រូវធ្វើឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈនិងឯកជន

- ធានាថា រាល់ទិន្នន័យនិងឯកសារភ្ជាប់ដែលបញ្ចូលក្នុងប្រព័ន្ធផ្តល់ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច មានភាពត្រឹមត្រូវ និងពុំមានការក្លែងបន្លំ
- រាយការណ៍រាល់ភាពមិនប្រក្រតីលើដំណើរការប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែទៅក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងរយៈពេលមិនលើសពី២៤(ម្ភៃបួន)ម៉ោង
- ផ្តល់កិច្ចសហការផ្សេងទៀតតាមការស្នើសុំរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួង ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា២៩ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិផ្អាក ឬលុបគណនីប្រើប្រាស់តាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែរបស់ម្ចាស់នាវាឬភ្នាក់ងារនាវា ក្នុងករណីរកឃើញថា ម្ចាស់នាវាឬភ្នាក់ងារនាវាបានប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ម្ចាស់នាវាឬភ្នាក់ងារនាវា អាចទទួលបានគណនីប្រើប្រាស់តាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែឡើងវិញ ក្នុងករណីបានកែសម្រួលឡើងវិញ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី២
## ក្រមសីលធម៌វិជ្ជាជីវៈនិងការរក្សាការសម្ងាត់

**មាត្រា៣០ .-**

មន្ត្រីអនុវត្តការងារពាក់ព័ន្ធនឹងការធ្វើបែបបទនាវា តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈដែលកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីពាក់ព័ន្ធត្រូវរក្សាការសម្ងាត់និងមិនត្រូវផ្សព្វផ្សាយព័ត៌មានឬឯកសារភ្ជាប់ដែលតម្រូវក្នុងអនុក្រឹត្យនេះដល់តតិយជនឡើយ លើកលែងតែមានការតម្រូវដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៣១ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ និងការធ្វើបែបបទនាវាចូលចេញ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៣២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១៣កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

Chanthol Sun

**ស៊ុន ចាន់ថុល**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ១១២ អនក្រ.បក ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០២៣
ស្ដីពីប្រព័ន្ធផ្លាស់ប្ដូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ
គំនូសបំព្រួញប្រព័ន្ធផ្លាស់ប្ដូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ




(១) ក្រុមហ៊ុននាវា តំណាងម្ចាស់នាវា ឬភ្នាក់ងារនាវា មានតួនាទីបញ្ចូលព័ត៌មានរបស់នាវា ដើម្បីស្នើសុំលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែនិងធ្វើបែបបទនាវាចូលចេញ។

(២) ក្រសួងសាធារណការនិងដឹកជញ្ជូន មានតួនាទីគ្រប់គ្រងប្រព័ន្ធ និងផ្ដល់លិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ។

(៣) គយនិងរដ្ឋាករកម្ពុជា អន្តោប្រវេសន៍ ចត្តាឡីស័ក មានតួនាទីត្រួតពិនិត្យនិងសម្រេចការស្នើសុំធ្វើបែបបទនាវាចូលចេញតាមជំនាញក្រសួង ស្ថាប័នមានសមត្ថកិច្ច។

(៤) កំពង់ផែ មានតួនាទីពិនិត្យនិងសម្រេចការស្នើសុំធ្វើបែបបទនាវាចូលចេញ។



អម

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ១១២ អនក្រ.បក ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ២០២៣
ស្តីពីប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ
គំនូសបំព្រួញនៃការស្នើសុំធ្វើបែបបទតាមប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ

